ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៥........សហវ.ឃ.

## សេចក្ដីណែនាំ
## ស្ដីពីការចុះបេសកកម្ម

ក្នុងគោលបំណងធានាកិត្យានុភាពនិងសេចក្ដីថ្លៃថ្នូររបស់ស្ថាប័ននិងមន្ត្រីរាជការសាធារណៈ កំណត់នូវគុណតម្លៃ និងសីលធម៌វិជ្ជាជីវៈ នៃការបំពេញការងារសាធារណៈ ដើម្បីលើកកំពស់ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ តម្លាភាព និង គណនេយ្យភាព នៃការបំពេញបេសកកម្ម នៅក្នុងប្រទេស និងក្រៅប្រទេស របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រី ជាប់កិច្ចសន្យានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ, ប្រកាសលេខ ៤៦៤ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២ ស្ដីពីដាក់ឱ្យអនុវត្តក្រមសីលធម៌មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីវិធាននិងនីតិវិធីនៃការអនុវត្ត ប្រាក់បេសកកម្ម ក្នុងប្រទេស និងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិ, ក្រសួងសូមធ្វើការណែនាំដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំក្រុមប្រឹក្សា គណៈកម្មការ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត អង្គភាពនិងមន្ត្រីរាជការក្រោម ឱវាទ ត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម ÷

១. ត្រូវប្រកាន់ខ្ជាប់នូវគុណតម្លៃវិជ្ជាជីវៈ និង គុណតម្លៃបុគ្គល ក្នុងការបំពេញមុខងារសាធារណៈ។
២. មិនត្រូវ ÷
- យកឥទ្ធិពល និង អំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុត គំរាមកំហែង
- ក្លែងបន្លំលិខិតយុត្តិការចំណាយ និងលិខិតស្នាមផ្សេងៗ ក្នុងគោលបំណងទទួលបានប្រាក់បេសកកម្ម ដែល ខ្លួនពុំមានសិទ្ធិទទួលតាមបញ្ញត្តិជាធរមាន
- បង្វែរ ឬកេងប្រវ័ញ្ចប្រាក់បេសកកម្ម ដើម្បីយកទៅប្រើប្រាស់ក្រៅពីការបំពេញបេសកកម្ម
- បង្កើនរយៈពេលបំពេញបេសកកម្ម និង/ឬ ចំនួនមន្ត្រីចុះបេសកកម្ម ដែលខុសពីបេសកកម្មដែលបាន បំពេញបេសកកម្មជាក់ស្ដែង
- បង្កើតបេសកកម្មដោយក្លែងបន្លំ ក្នុងគោលបំណងទទួលបានប្រាក់ឧបត្ថម្ភបន្ថែម
- ទទួលប្រាក់បេសកកម្មដោយមិនបានផ្ដល់ជូនសាមីមន្ត្រីរាជការសាធារណៈដែលត្រូវបំពេញបេសកកម្ម
- រារាំង ឬព្យាយាមរារាំង ដល់ដំណើរការត្រួតពិនិត្យប្រក្រតីភាពនៃការអនុវត្តប្រាក់បេសកកម្ម។

ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការគ្រប់រូប គ្រប់លំដាប់ថ្នាក់ នៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ត្រូវអនុវត្តសេចក្ដីណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- គ្រប់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងវិទ្យាស្ថាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី-ខេត្ត
- គ្រប់សាខាគយនិងរដ្ឋាករ សាខាពន្ធដារ និងរតនាគាររាជធានី-ខេត្ត
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ [illegible]

# ប្រកាស
## ស្តីពីការដាក់ឱ្យអនុវត្ត
## ក្រមសីលធម៌មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារនិងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax 855-23-427 798

## សម្រេច

**ប្រការ ១**.- ដាក់ឱ្យអនុវត្តក្រមសីលធម៌មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចដែលមានខ្លឹមសារភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២**.-គ្រប់មន្ត្រីរាជការក្របខ័ណ្ឌនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គលិកកិច្ចសន្យានិងពលករអណ្តែតដែលត្រូវបានជ្រើសរើសដើម្បីបំពេញការងារក្នុងអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន ក្រុមប្រឹក្សា គណៈកម្មាធិការ គណៈកម្មការ នាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងគ្រប់អង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវគោរពនិងប្រតិបត្តិការងារ ដោយអនុលោមតាមក្រមសីលធម៌មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានបញ្ជាក់ក្នុង **ប្រការ ១** នៃប្រកាសនេះ។

**ប្រការ ៣**.-អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន អគ្គាធិការ នាយកវិទ្យាស្ថាន ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងគ្រប់ប្រធានអង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២

គាត ឈន់

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ឯកឧត្តមរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ក្រមសីលធម៌

## មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

មុខងារសាធារណៈគឺជាស្ថាប័នដ៏សំខាន់នៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការផ្ដល់សេវាសាធារណៈ មន្ត្រីរាជការបានរួមចំណែកយ៉ាងសំខាន់ដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល, ការអភិវឌ្ឍប្រទេសជាតិ និង ការលើកស្ទួយវិបុលភាពសង្គម។ ដោយឡែក មន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីផ្សារភ្ជាប់ដោយផ្ទាល់ជួយដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល លើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីអនុវត្តមុខងារនិងបេសកកម្មក្រសួងឱ្យមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពក្នុងក្របខ័ណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។ មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានបេសកកម្មក្នុងក្របខ័ណ្ឌមុខងារសាធារណៈជួយដល់ប្រធានស្ថាប័នដើម្បីបម្រើផលប្រយោជន៍សាធារណៈស្របតាមបទប្បញ្ញត្តិច្បាប់។

ក្នុងស្មារតីនេះ ក្រមសីលធម៌មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានគាក់តែងនិងដាក់ឱ្យអនុវត្តជាជំនួយដល់ការគ្រប់គ្រងការបំពេញវិជ្ជាជីវៈរបស់មន្ត្រីម្នាក់ៗ ក្រោមក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០២.នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤, ច្បាប់ស្ដីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៦នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤, ច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦, ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨, ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០, ព្រមទាំងគោលការណ៍ដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់និងវិធានបទបញ្ញាពាក់ព័ន្ធជាធរមាន ។

## ១. គោលបំណង

ក្រមសីលធម៌មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កំណត់នូវគុណតម្លៃនិងសីលធម៌វិជ្ជាជីវៈនៃការបំពេញការងារក្នុងមុខងារសាធារណៈដើម្បីជាមគ្គុទ្ទេសក៍និងគាំទ្រមន្ត្រីរាជការក្រសួងក្នុងគ្រប់សកម្មភាពការងារវិជ្ជាជីវៈ ការលើកស្ទួយឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈនិងវប្បធម៌សេវាសាធារណៈ។ ក្រមសីលធម៌នេះត្រូវយកទៅអនុវត្តដើម្បីរក្សានិងលើកតម្កើងភាពទុកចិត្តរបស់សាធារណជនចំពោះគុណភាពនិងសុចរិតភាពនៃសេវាសាធារណៈ



[illegible]

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
N°92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855 23 724 664 Fax: 855 23 427 798

ដែលផ្តល់ដោយក្រសួង តាមរយៈការពង្រឹងដំណើរការរដ្ឋបាលឱ្យកាន់តែមានតម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព។ ក្រមសីលធម៌នេះត្រូវអនុវត្តផងដែរដើម្បីពង្រឹងការគោរពនិងការឱ្យតម្លៃចំពោះតួនាទីដែលមន្ត្រីរាជការម្នាក់ៗត្រូវបំពេញក្នុងមុខងារសាធារណៈរបស់ក្រសួង។

## ២. គុណតម្លៃសេវាសាធារណៈ

ក្នុងតួនាទីជាអ្នកបម្រើផលប្រយោជន៍សាធារណៈ មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវប្រកាន់ឥរិយាបទវិជ្ជាជីវៈនិងប្រតិបត្តិមុខងារក្នុងបរិស្ថានការងារ ដោយផ្អែកតាមគុណតម្លៃដូចខាងក្រោម÷

### ២.១ គុណតម្លៃវិជ្ជាជីវៈ

មន្ត្រីរាជការត្រូវបង្ហាញនូវវិជ្ជាជីវភាពក្នុងមុខងារនិងបំពេញការងារប្រកបដោយសមត្ថភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព វត្ថុវិស័យភាព និង អនាគតិ ដោយត្រូវ÷

- គោរពនិងប្រតិបត្តិដោយត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់និងបទប្បញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា ព្រមទាំងរក្សាឱ្យបាននូវអព្យាក្រឹតភាពនៃសេវាសាធារណៈ
- គាំទ្រដល់ប្រធានស្ថាប័នក្នុងការរៀបចំនិងអនុវត្តគោលនយោបាយ និងការផ្តល់សេវាសាធារណៈ
- ផ្តល់យោបល់ តាមលំដាប់ឋានានុក្រមការងារ ដោយស្មោះត្រង់ មិនលម្អៀង ផ្តល់នូវគ្រប់ព័ត៌មានពាក់ព័ន្ធផ្អែកតាមមូលដ្ឋានដែលមានអំណះអំណាងជាក់លាក់ និងបង្ហាញដោយច្បាស់លាស់អំពីអង្គហេតុនិងជម្រើសផ្សេងៗដែលអាចមាន ដើម្បីជួយដល់ការធ្វើសេចក្តីសម្រេចរបស់ប្រធានអង្គភាពនិងប្រធានស្ថាប័ន
- បំពេញភារកិច្ចដោយសុចរិតភាពនិងអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រសួងដោយស្មោះត្រង់និងត្រឹមត្រូវតាមបញ្ញត្តិច្បាប់
- គោរពវិន័យការងារបានត្រឹមត្រូវ បំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់និងប្រឹងប្រែងផ្តល់សមិទ្ធកម្មអស់ពីកំលាំងកាយ ចិត្ត និងប្រាជ្ញា
- មិនត្រូវរើសអើងដោយមិនសមស្របតាមរយៈការផ្តល់នូវផលប្រយោជន៍ឬបុព្វសិទ្ធិពិសេសដល់បុគ្គលណាមួយ ទោះតាមរូបភាពហិរញ្ញវត្ថុ ឬ មិនមែនហិរញ្ញវត្ថុ
- មិនត្រូវប្រើអំណាចបំពានហួសតួនាទីនិងសមត្ថកិច្ចរបស់ខ្លួន ក្នុងពេលបំពេញភារកិច្ច
- មិនត្រូវផ្តល់ព័ត៌មានអំពីកិច្ចការក្នុងមុខងារផ្លូវការរបស់ខ្លួន ដល់បុគ្គលខាងក្រៅ ឬ សាធារណជនដោយពុំមានការអនុញ្ញាតពីប្រធានស្ថាប័ន
- ធានាការប្រើប្រាស់ធនធានសាធារណៈដោយត្រឹមត្រូវ មានប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពដោយប្រឹងប្រែងរិះរកនិងប្រើប្រាស់ធនធាននិងមធ្យោបាយដោយសន្សំសំចៃនិងមានប្រសិទ្ធភាពខ្ពស់ក្នុងការសម្រេចកិច្ចការ

- លើកស្ទួយគុណភាពសេវាជាប្រចាំ ដោយសម្របតាមតម្រូវការនៃការផ្លាស់ប្តូរតាមរយៈនវានុវត្តន៍ និងការកែលម្អប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃកម្មវិធីនិងសេវាទាំងឡាយរបស់ក្រសួង
- ក្នុងការបំពេញមុខងារនិងការទទួលខុសត្រូវជាផ្លូវការ ត្រូវធ្វើការសម្រេចទាំងឡាយជាប្រយោជន៍សាធារណៈ
- ក្នុងពេលបំពេញភារកិច្ច ត្រូវស្លៀកសំលៀកបំពាក់សមរម្យ ឬ មានឯកសណ្ឋានសមស្រប និង មានប័ណ្ណសំគាល់មន្ត្រីរាជការ តាមការតម្រូវ ឬ អនុញ្ញាតរបស់អង្គភាព និងមិនត្រូវប្រើប្រាស់ឯកសណ្ឋាននិងប័ណ្ណសំគាល់មន្ត្រីរាជការនៅក្រៅពេលបំពេញភារកិច្ចនិងក្នុងទីកន្លែងមិនសមរម្យឡើយ។

## ២.២ គុណតម្លៃបុគ្គល

មន្ត្រីរាជការត្រូវបង្ហាញនូវការគោរព ភាពយុត្តិធម៌ និង សុភាពរាបសារក្នុងទំនាក់ទំនងជាមួយអ្នកប្រើប្រាស់សេវាសាធារណៈនិងសហសេវិករបស់ខ្លួន ដោយត្រូវ÷

- គោរពសេចក្តីថ្លៃថ្នូរនិងតម្លៃរបស់បុគ្គលម្នាក់ៗក្នុងពេលបំពេញភារកិច្ច ឬ ប្រើប្រាស់អំណាចសាធារណៈ
- លើកតម្កើងតម្លៃបុគ្គលក្នុងសេវាសាធារណៈឱ្យបានទូលំទូលាយ
- ក្នុងការដឹកនាំនិងគ្រប់គ្រងអង្គភាព ជំរុញឱ្យមានការចូលរួម ភាពបើកទូលាយ ការទំនាក់ទំនង និងមានការគោរពចំពោះគ្នាទៅវិញទៅមក ព្រមទាំងសាមគ្គីភាពផ្ទៃក្នុងល្អ
- ទទួលស្គាល់គុណសម្បត្តិការងារជាមូលដ្ឋានចំបងនៃការលើកទឹកចិត្ត ។

## ២.៣ បរិស្ថានការងារ

អង្គភាពបំពេញការងារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវមានអនាម័យ សោភ័ណភាព និងជាកន្លែងធ្វើការគ្មានផ្សែងបារី ។ ល្បែងស៊ីសងគ្រប់ប្រភេទនិងរាល់សកម្មភាពដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបុគ្គលនិងសង្គមឬរំខានដល់ការបំពេញការងារ ត្រូវបានហាមឃាត់ក្នុងបរិវេណនៃអង្គភាពចំណុះក្រសួង។ ទន្ទឹមនេះក្នុងពេលបំពេញភារកិច្ចមន្ត្រីរាជការក្រសួង មិនត្រូវស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងនិងគ្រឿងញៀនឡើយ។

## ៣. វិធានការណ៍អនុវត្ត

មន្ត្រីរាជការម្នាក់ៗត្រូវធានាថាគ្រប់សកម្មភាពសេវាសាធារណៈ ត្រូវមានសង្គតិភាពទៅនឹងគោលការណ៍និងគុណតម្លៃនៃក្រមសីលធម៌នេះ។ បន្ថែមលើបទប្បញ្ញត្តិដែលមានចែងក្នុងក្រមសីលធម៌នេះ មន្ត្រីរាជការត្រូវប្រតិបត្តិខ្លួនផងដែរដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ និងវិធានបទបញ្ជាទាំងឡាយដែលគ្រប់គ្រងអង្គភាពនិងវិជ្ជាជីវៈរបស់ខ្លួន តាមករណីដែលមានជាក់ស្តែង។ ៥/

### ៣.១ ការទទួលខុសត្រូវ សមត្ថកិច្ច និង គណនេយ្យភាព

ដើម្បីធានាការគោរពនិងអនុវត្តក្រមសីលធម៌នេះឱ្យមានប្រសិទ្ធភាព មន្ត្រីរាជការក្រសួងត្រូវប្រតិបត្តិតាមវិធានដូចខាងក្រោម ÷

- នៅពេលមន្ត្រីម្នាក់ត្រូវបានក្រសួងទទួលស្គាល់ជាកម្មសិក្សាការី មន្ត្រីនោះនឹងត្រូវប្រាប់ឱ្យដឹងនិងត្រូវទទួលស្គាល់ថា ក្រមសីលធម៌មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាលក្ខខណ្ឌមួយនៃការចូលបំពេញការងារ
- ធានាឱ្យបានការគោរពតាមក្រមសីលធម៌នេះ និងធ្វើជាគំរូក្នុងគ្រប់សកម្មភាពនិងឥរិយាបទរបស់ខ្លួន ក្នុងការលើកតម្កើងតម្លៃនៃសេវាសាធារណៈ
- គ្រប់មន្ត្រីរាជការក្រសួង ត្រូវមានគណនេយ្យភាពចំពោះថ្នាក់ដឹកនាំតាមលំដាប់ឋានានុក្រម និងគណនេយ្យភាពចំពោះប្រធានស្ថាប័ន និងផ្តល់នូវព័ត៌មានអំពីលទ្ធផលនៃការងាររបស់ខ្លួនដល់ថ្នាក់ដឹកនាំដែលគ្រប់គ្រងផ្ទាល់ដោយទៀងទាត់និងជាប្រចាំ
- ថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់គ្រងអង្គភាពនៅគ្រប់លំដាប់ ត្រូវផ្សព្វផ្សាយក្រមសីលធម៌ឱ្យបានជ្រួតជ្រាបដល់មន្ត្រីរាជការក្រោមឱវាទ ធ្វើការរំលឹកប្រចាំឆ្នាំ និង បញ្ជ្រាបតម្លៃនៃក្រមសីលធម៌ទាំងនេះក្នុងគ្រប់ទិដ្ឋភាពការងារនៃអង្គភាព ព្រមទាំងធានាឱ្យមានការគោរពនិងអនុវត្តផងដែរ។ ថ្នាក់ដឹកនាំនិងមន្ត្រីគ្រប់គ្រងអង្គភាព ក៏អាចប្រកាន់យកវិធានការបន្ថែមផ្សេងទៀតដើម្បីឆ្លើយតបនឹងតម្រូវការដោយឡែករបស់អង្គភាព ឬលក្ខន្តិកៈដែលគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាព បន្ទាប់ពីមានការឯកភាពពីប្រធានស្ថាប័ន។

### ៣.២ ការងារ ឬ សកម្មភាពក្រៅមុខងារសាធារណៈ

មន្ត្រីរាជការ អាចបំពេញការងារក្រៅមុខងារសាធារណៈ និងចូលរួមក្នុងសកម្មភាពខាងក្រៅបាន ប្រសិនបើមិនប៉ះពាល់ ឬ ធ្វើឱ្យកើតមានទំនាស់ផលប្រយោជន៍ ឬ អព្យាក្រឹតភាពនៃសេវាសាធារណៈ ឬ មិនមានការហាមឃាត់ដោយបទប្បញ្ញត្តិច្បាប់។

### ៣.៣ ទិដ្ឋានបញ្ចៀសទំនាស់ផលប្រយោជន៍

ដើម្បីបញ្ចៀសនិងបង្ការស្ថានភាពដែលអាចនាំឱ្យមានទំនាស់ផលប្រយោជន៍ ឬ មន្ទិលចំពោះការនាំឱ្យកើតមានទំនាស់ផលប្រយោជន៍ មន្ត្រីរាជការ ត្រូវប្រតិបត្តិដូចខាងក្រោម÷

- ក្នុងពេលបំពេញមុខងារជាផ្លូវការ មន្ត្រីរាជការត្រូវចាត់ចែងកិច្ចការផ្ទាល់ខ្លួនកុំឱ្យមានផលប៉ះពាល់ដល់ស្ថានភាពនៃទំនាស់ផលប្រយោជន៍
- ប្រសិនបើទំនាស់កើតមានរវាងផលប្រយោជន៍ឯកជននិងមុខងារជាផ្លូវការរបស់ខ្លួន ទំនាស់ត្រូវដោះស្រាយដោយផ្តល់តម្លៃដល់ប្រយោជន៍សាធារណៈជាធំ

- មិនត្រូវទទួលផលប្រយោជន៍ឯកជន ផ្សេងក្រៅពីអ្វីដែលច្បាប់អនុញ្ញាត ដែលធ្វើឱ្យប៉ះពាល់សកម្មភាពរដ្ឋបាលដែលខ្លួនបំពេញ ឬ ចូលរួម
- មិនត្រូវជួយដល់អង្គភាព ឬ បុគ្គលឯកជនក្នុងទំនាក់ទំនងជាមួយអាជ្ញាធររដ្ឋបាលដើម្បីទទួលប្រយោជន៍ ឬ ការប្រព្រឹត្តជាពិសេសចំពោះអង្គភាព ឬ បុគ្គលនោះ
- មិនត្រូវទទួលនូវផលប្រយោជន៍ពីព័ត៌មានដែលបានដឹងក្នុងក្របខ័ណ្ឌការងារផ្លូវការ ដែលព័ត៌មាននោះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ
- មិនត្រូវបំពេញសកម្មភាពពាណិជ្ជកម្មជាមួយរដ្ឋបាលសាធារណៈទោះដោយផ្ទាល់ ឬ ប្រយោល ដែលផ្ទុយនឹងការបំពេញមុខងារផ្លូវការរបស់សាមីជន
- រាយការណ៍ ក្នុងរយៈពេល ៣០ ថ្ងៃនៃការតែងតាំងដំបូងរបស់ខ្លួន ឬ ការតែងតាំងក្រោយៗទៀត ឬ ការផ្ទេរ/ផ្លាស់ប្តូរភារកិច្ច អំពីគ្រប់សកម្មភាពខាងក្រៅនិងកាតព្វកិច្ចទាំងឡាយដែលអាចមានទំនាស់ផលប្រយោជន៍ជាមួយការបំពេញមុខងារជាផ្លូវការ។ របាយការណ៍ត្រូវផ្តល់ជូនទៅប្រធានអង្គភាពដែលគ្រប់គ្រងផ្ទាល់និងនាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រូវពិនិត្យឡើងវិញកាតព្វកិច្ចរបស់ខ្លួនក្រោមក្រមសីលធម៌នេះ គ្រប់ពេលមានការផ្លាស់ប្តូរក្នុងកិច្ចការផ្ទាល់ខ្លួន ឬ ភារកិច្ចផ្លូវការ។ ប្រសិនបើទំនាស់ផលប្រយោជន៍មានពិតជាក់ស្តែង ឬ ដែលនឹងកើតមានពិតប្រាកដនោះ មន្ត្រីរាជការនោះត្រូវរាយការណ៍ជាថ្មីអំពីស្ថានភាពនេះ ។

## ៤. អានុភាពអនុវត្ត

ក្រមសីលធម៌មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានអានុភាពអនុវត្តដូចខាងក្រោម÷

- នឹងត្រូវបកស្រាយនិងយកទៅអនុវត្តក្នុងក្របខ័ណ្ឌនៃលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជានិងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- អនុវត្តចំពោះគ្រប់មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបម្រើការងារនៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន ក្រុមប្រឹក្សា គណៈកម្មាធិការ គណៈកម្មការ នាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន មន្ទីរ និង អង្គភាព ចំណុះក្រសួង ។
- ត្រូវបានចាត់ទុកជាផ្នែកមួយនៃគោលនយោបាយគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយឡែក អង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានបង្កើត និង អនុវត្ត ឬ នឹងបង្កើតក្រមសីលធម៌ផ្ទាល់គ្រប់គ្រងមន្ត្រីរាជការក្រោមឱវាទ ត្រូវគោរពតាមស្មារតីនៃក្រមសីលធម៌នេះ និងកែសម្រួល ឬ អនុម័តនូវបទប្បញ្ញត្តិដែលមានលក្ខណៈប្រហាក់ប្រហែលសម្រាប់អង្គភាពរបស់ខ្លួន ។

មន្ត្រីរាជការ ដែលមិនប្រតិបត្តិតាមគុណតម្លៃនិងសីលធម៌វិជ្ជាជីវៈនៃក្រមសីលធម៌នេះ នឹងត្រូវប្រឈមនឹងទណ្ឌកម្មវិន័យដូចមានចែងក្នុងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការ និងទណ្ឌកម្មដទៃទៀតផ្អែកបទប្បញ្ញត្តិច្បាប់ជាធរមាន។ ៚

.....................